រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

054KH01A-01

ការរៀបចំរូបកាយរបស់ព្រះគ្រីស្ត



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

២៣

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



ការរៀបចំរូបកាយរបស់ព្រះគ្រីស្ត

កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

ទូលសូមអោយព្រះជាម្ចាស់ជួយក្រុមជំនុំរបស់អ្នក អោយអាចមានការរៀបចំល្អ ដែលថ្វាយកិត្តិយស និងសិរីរុងរឿងដល់ព្រះអង្គ ។

តើក្រុមជំនុំជាកម្មសិទ្ធិរបស់នរណា ?

ព្រះគ្រីស្តជាព្រះសិរសារបស់ក្រុមជំនុំ

ក្រុមជំនុំជារូបកាយរបស់ព្រះអង្គ (អេភេសូ ៥:២៣-៣៣) ។ ព្រះគ្រីស្តជាម្ចាស់ និងជាអ្នកគ្រប់គ្រងក្រុមជំនុំ ។ ព្រះអង្គបានលោះក្រុមជំនុំ ដោយព្រះលោហិតរបស់ព្រះអង្គ ។ ព្រះអង្គជាមេបញ្ជាការលើក្រុមជំនុំ ។ ក្រុមជំនុំផ្សារភ្ជាប់ជាមួយព្រះអម្ចាស់ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ ។



ព្រះគ្រីស្តជាសិរសា ដឹកនាំរូបកាយរបស់ព្រះអង្គ ។ ព្រះអង្គបង្រៀនយើងតាមរយៈព្រះបន្ទូលរបស់ព្រះអង្គ ដែលជាព្រះគម្ពីរ។ ព្រះអង្គដឹកនាំយើង និងប្រទានឫទ្ធានុភាពដល់យើង ឱ្យអាចធ្វើតាមសេចក្តីបង្គាប់របស់ព្រះអង្គ តាមរយៈ**ព្រះវិញ្ញាណដ៏វិសុទ្ធ** ។ ដូច្នេះ គឺព្រះយេស៊ូដឹកនាំក្រុមជំនុំរបស់ព្រះអង្គ និងជួយក្រុមជំនុំអោយរីកចំរើនទៅមុខ ។

ព្រះគ្រីស្តមិនគ្រាន់តែជាម្ចាស់លើក្រុមជំនុំប៉ុណ្ណោះទេ គឺព្រះអង្គជាមេដឹកនាំ ជាស្វាមី និងជាព្រះមហាក្សត្រជាទីស្រឡាញ់របស់ក្រុមជំនុំ ។ ព្រះអង្គជាមេបញ្ជាការលើក្រុមជំនុំ នៅគ្រប់កាលៈទេសៈទាំងអស់ ។ មានតែព្រះអង្គប៉ុណ្ណោះ ដែលមានអំណាចនេះ គឺថាក្រុមជំនុំគ្មានព្រះសិរសាផ្សេងទៀតទេ ។ ក្រុមជំនុំត្រូវប្រតិបត្តិតាមតែព្រះអង្គមួយប៉ុណ្ណោះ ។

ហេតុអ្វីបានជាមនុស្សគ្មានសិទ្ធិបង្កើតក្រិត្យវិន័យសំរាប់ក្រុមជំនុំ ?

កំណត់ចំណាំ :



© Project WorldReach © SEAN

បង្រៀនពួកអ្នកជឿថ្មី ការថ្វាយបង្គំ ការប្រកបគ្នា និង ការជួយអ្នកខ្វះខាត ។



- បញ្ជូលលអ្នកចាស់ទុំខ្លះៗ អោយចូលរួមក្នុងកម្មវិធីបង្ហាត់បង្រៀនគ្រូគង្វាល គឺ « កម្មវិធីបង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត » ។
- ជួយលេខា និងហេរញ្ញិករៀបចំបញ្ជី ដើម្បីកត់ត្រាចំនួនសមាជិក ដែលចូលរួមក្នុងការប្រជុំ អ្នកជឿទាំងអស់ដែលទទួលពិធីជ្រមុជទឹក ចំនួនសមាជិកទូទៅ ចំណូល និងចំណាយ ។

ជំហានទីមួយ

ព្រះគ្រីស្តជាព្រះសិរសារបស់ក្រុមជំនុំ ។ ហេតុនេះហើយបានជា **ជំហានទីមួយ**នៃការរៀបចំក្រុមជំនុំថ្មី គឺ : **ក្រុមជំនុំទាំងមូលត្រូវប្តេជ្ញាប្រតិបត្តិតាមព្រះគ្រីស្ត** ។

តើក្រុមជំនុំជាអ្វី ?

ក្រុមជំនុំជាក្រុមអ្នកជឿ ដែលប្រតិបត្តិតាមព្រះគ្រីស្ត ។ ពួកអ្នកជឿទាំងនោះ ជារូបកាយរបស់ព្រះគ្រីស្ត ។

ក្រុមជំនុំផ្សារភ្ជាប់ជាមួយព្រះគ្រីស្តតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ ។

☐ សូមអានម៉ាថាយ ២៨:១៨-២០ និង ១ កូរិនថូស ១២:១២-១៣ ។

នៅពេលដែលយើងគោរពចុះចូលចំពោះព្រះអម្ចាស់យេស៊ូគ្រីស្ត ព្រះអង្គនឹងប្រទានឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធមកយើង ដើម្បីអោយយើងអាចប្រតិបត្តិតាមព្រះអង្គ ។

សិស្សរបស់ព្រះអម្ចាស់យេស៊ូ គឺជាក្រុមជំនុំ ។



ការប្រតិបត្តិតាម

ឫទ្ធានុភាព

ក្រុមជំនុំ : រូបកាយរបស់ព្រះគ្រីស្ត

សិស្សរបស់ព្រះគ្រីស្ត គឺជាពួកអ្នកជឿដែលស្រឡាញ់ព្រះអង្គ និងគោរពតាមសេចក្តីបង្គាប់របស់ព្រះអង្គ ។ យើងអាចសង្ខេបសេចក្តីបង្គាប់របស់ព្រះអម្ចាស់ សំរាប់ក្រុមជំនុំដែលនៅក្នុងសម្ពន្ធមេត្រីថ្មី ដូចតទៅ :

- កែប្រែចិត្តគំនិត ហើយជឿលើព្រះយេស៊ូ ។ (ម៉ាកុស ១:១៥)

ការរៀបចំការងារយុវជន ការបង្កើតក្រុមជំនុំសាខាមួយ ការរៀបចំកម្មវិធីថ្វាយបង្គំ ការរៀបចំការងារសង្គមកិច្ច ។ល។) ហើយសរសេរថែមទៀតអំពីអ្នកដែលទទួលខុសត្រូវ ក្នុងការដឹកនាំការប្រជុំសំរាប់ពួកអ្នកចាស់ទុំ និងអ្នកដែលធ្វើជាលេខា (សំរាប់កត់សេចក្តីសំរេច) ។

ឈ្មោះ : _____ កិច្ចការបំរើ : _____
ឈ្មោះ : _____ កិច្ចការបំរើ : _____
ឈ្មោះ : _____ កិច្ចការបំរើ : _____
ឈ្មោះ : _____ កិច្ចការបំរើ : _____
ឈ្មោះ : _____ កិច្ចការបំរើ : _____
ឈ្មោះ : _____ កិច្ចការបំរើ : _____
ឈ្មោះ : _____ កិច្ចការបំរើ : _____
ឈ្មោះ : _____ កិច្ចការបំរើ : _____

- ត្រូវធ្វើយ៉ាងណាឱ្យក្រុមជំនុំទទួលបានពត៌មាន ជាទៀងទាត់ពីការងាររបស់ពួកអ្នកចាស់ទុំ ដើម្បីអោយក្រុមជំនុំអធិស្ឋានអោយពួកអ្នកចាស់ទុំទាំងអស់នោះ ។
- ជួបប្រជុំទៀងទាត់ជាមួយក្រុមអ្នកចាស់ទុំ (ក្រុមប្រឹក្សា ឬ គណៈកម្មាធិការ) ដើម្បីរៀបចំការងារផ្សាយដំណឹងល្អ ការ

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- **បង្រៀនក្រុមជំនុំរបស់អ្នក អោយចេះអនុវត្តជំហានទាំងប្រាំនៃការរៀបចំក្រុមជំនុំ :**

  ១- ក្រុមទាំងមូលត្រូវប្តេជ្ញាប្រតិបត្តិតាមព្រះគ្រីស្ត ដោយអំណាចនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។

  ២- ចាត់តាំងអ្នកដឹកនាំ (ជាធម្មតា ហៅថាអ្នកចាស់ទុំ) អោយឃ្វាល និង បង្រៀនសមាជិកអោយចេះប្រតិបត្តិតាមព្រះគ្រីស្ត ។

  ៣- បញ្ជូល និង ចាត់ចែងមុខងារបំរើខាងផ្សាយដំណឹងល្អ ជាមួយនឹងមុខងារបំរើខាងកសាងពួកអ្នកជឿ ។

  ៤- អប់រំប្រៀនប្រដៅយ៉ាងមុតមាំ ។

  ៥- លើកទឹកចិត្ត និងជួយអោយសមាជិករបស់ខ្លួនទាំងអស់យកអំណោយទានរបស់ខ្លួនមកអនុវត្ត ។

- សូមសរសេរឈ្មោះរបស់អ្នកចាស់ទុំរបស់ក្រុមជំនុំអ្នក និងកិច្ចការបំរើរបស់ពួកគេ (ឧទាហរណ៍ : ការរៀបចំកម្មវិធីសួរសុខទុក្ខ ដើម្បីផ្សាយដំណឹងល្អ ការបង្រៀនអ្នកជឿថ្មី

- ទទួលពិធីជ្រមុជទឹក ។
  (ម៉ាថាយ ២៨:១៨-២០, កិច្ចការ ២:៣៧-៣៨)

- ស្រឡាញ់ព្រះជាម្ចាស់ និង មនុស្សឯទៀត ។
  (ម៉ាថាយ ២២:៣៤-៤០)

- ចែកចាយ និង អោយ ។
  (លូកា ១២:៣៣-៣៤)

- អធិស្ឋាន និង អានព្រះបន្ទូលព្រះជាម្ចាស់ ។ (ម៉ាថាយ ៤:៤, ៦:៥-១៣)

- ជួបជុំគ្នា និង ធ្វើពិធីកាច់នំបុ័ង ។
  (លូកា ២២:១៧-២០, ហេប្រឺ ១០:២៤-២៥)

- ផ្សព្វផ្សាយដំណឹងល្អ និងបង្កើតសាវ័ក ។
  (ម៉ាថាយ ២៨:១៨-២០) ។

នេះជាភារៈកិច្ចរបស់សមាជិកក្រុមជំនុំគ្រប់រូប **គឺសមាជិកទាំងអស់ត្រូវគោរពតាមសេចក្តីបង្គាប់ទាំងនេះ** ។

ក្រុមជំនុំ ជាអ្នកជឿដែល :

☐ គ្រាន់តែស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

☐ ប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។

ជំហានទីពីរ

ពួកអ្នកជឿ ដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត ជារូបកាយរបស់ព្រះអង្គ ។ ហេតុនេះហើយ ទើប**ជំហានទីពីរ**នៃការរៀបចំក្រុមជំនុំថ្មី គឺ : **ចាត់តាំងអ្នកដឹកនាំឱ្យឃ្វាល និងបង្រៀនសមាជិកអោយចេះប្រតិបត្តិតាមព្រះយេស៊ូ** ។

តើក្រុមជំនុំត្រូវចាត់អោយអ្នកណាជួយដឹកនាំការងារក្នុងក្រុមជំនុំ ?

កំណត់ចំណាំ : ក្រុមជំនុំផ្សេងៗមានរបៀបរៀបចំផ្សេងៗគ្នា ។ សូមផ្លាស់ប្តូរកិច្ចការក្នុងផ្នែកនេះ តម្រូវទៅតាមស្ថានភាពរបស់អ្នក ។

ព្រះជាម្ចាស់ប្រទានឱ្យអ្នកជឿមានមុខងារដឹកនាំផ្សេងៗ (អេភេសូ ៤:១១-១៦) ។

២១- ជំហានទីពីរ គឺនាំអ្នកចាស់ទុំម្នាក់ ឬពីរនាក់ទៅជាមួយ :

☐ ដើម្បីដាស់តឿនដោយសុភាពរាបសា ។

☐ ដើម្បីសងសឹកដោយកំហឹង ។ (រ៉ូម ១២:១៩)

២២- ជំហានទីបី គឺក្រុមជំនុំទាំងមូលត្រូវដោះស្រាយបញ្ហា ។ បើសិនជាគ្រីស្តជននោះមិនព្រមស្តាប់ គាត់ត្រូវ :

☐ ចេញពីក្រុមជំនុំ រហូតដល់គាត់កែប្រែចិត្តគំនិតវិញ ។

☐ ទទួលការអប់រំប្រៀនប្រដៅបីខែ ។

២៣- យើងអប់រំប្រៀនប្រដៅ ដើម្បី :

☐ ទិតៀន និងដេញចេញរហូត ។

☐ កែតម្រូវ និងស្តារឡើងវិញ ។

២៤- សិក្សា ១ ពេត្រុស ៥:១-៥ ដើម្បីរកចំណុចសំខាន់បី ឬ បួន អំពីអ្នកចាស់ទុំ ។ សូមសរសេរចំណុចទាំងនេះ នៅខាងក្រោម :

_____

_____

© Project WorldReach © SEAN

ព្រះជាម្ចាស់មិនចាត់តាំងអ្នកចាស់ទុំនៅក្នុងក្រុមជំនុំ ឱ្យធ្វើកិច្ចការគ្រប់យ៉ាងទេ តែអោយបង្រៀនពួកអ្នកជឿឯទៀត អោយមានលក្ខណៈគ្រប់គ្រាន់វិញ ដើម្បីឱ្យគេទាំងអស់គ្នាអាចមានចំណែកក្នុងការងាររបស់ក្រុមជំនុំបានដែរ ។



នៅក្នុងព្រះគម្ពីរពាក្យ «អ្នកចាស់ទុំ» មិនមែនមានន័យថាមនុស្សចាស់នោះទេ តែមានន័យថា មនុស្សចាស់ទុំទាំងខាងព្រលឹងវិញ្ញាណ ទាំងខាងការបំរើព្រះជាម្ចាស់ និងមនុស្សឯទៀត ។ អ្នកចាស់ទុំជាមនុស្ស ដែលថ្វាយខ្លួនទាំងស្រុងទៅព្រះជាម្ចាស់ ហើយយកចិត្តទុកដាក់ដឹកនាំការងាររបស់ក្រុមជំនុំមួយ (កិច្ចការ ២០: ១៧, ២៨) ។

១៧- យើងតែងតាំងអ្នកចាស់ទុំ ដើម្បីអោយ :

- ☐ ធ្វើការងារឃ្វាល ។
- ☐ មានឋានៈមួយនៅក្នុងគណៈកម្មាធិការមួយ ។

១៨- ភារៈកិច្ចទីមួយដែលអ្នកចាស់ទុំត្រូវធ្វើ ដើម្បីក្រុមជំនុំរបស់ខ្លួន គឺ :

- ☐ ត្រួតត្រាក្រុមជំនុំ ។
- ☐ ថែរក្សា និង បំរើក្រុមជំនុំ ។

១៩- ដើម្បីអាចដឹកនាំការងារក្នុងក្រុមជំនុំ ពួកអ្នកចាស់ទុំត្រូវ :

- ☐ បង្ខំ ដាក់ទោស និងធ្វើបទបញ្ជាជាច្រើនសំរាប់ត្រួតត្រាមនុស្ស ។
- ☐ អធិស្ឋាន សិក្សា ជួបជុំ និងណែនាំប្រមូលក្រុមជំនុំ ។

២០- ជំហានទីមួយសំរាប់ការកែតម្រង់គ្រីស្តជន គឺ :

- ☐ និយាយជាមួយគាត់តែពីរនាក់ ។
- ☐ ទិតៀនគាត់ ។

ក្រុមជំនុំខ្លះមិនប្រើពាក្យ «អ្នកចាស់ទុំ» ទេ ។ ពួកគេហៅពួកអ្នកដែលជួយទទួលខុសត្រូវក្នុងការឃ្វាល ឬ ការដឹកនាំក្រុមជំនុំថា : គ្រូគង្វាល អ្នកដឹកនាំ អ្នកជំនួយ អ្នកបំរើកិច្ចការ ឬ ពួកព្រឹទ្ធាចារ្យ ។

ពាក្យដែលគេប្រើសំរាប់ហៅអ្នកចាស់ទុំមិនសំខាន់ទេ ការសំខាន់គឺពួកគេបំពេញភារៈកិច្ចឃ្វាលរបស់ពួកគេ ។ ភារៈកិច្ចទាំងនោះគឺអ្នកចាស់ទុំថែរក្សា និងបង្រៀនក្រុមជំនុំ : (កិច្ចការ ១៤:២៣, ២០:១៧-២៨, អេភេសូ ៤:១១, ១ ធីម៉ូថេ ៥:១៧, ទីតុស ១:៥-៩, ១ ពេត្រុស ៥:១-៥) ។ ពួកអ្នកចាស់ទុំទៅសួរសុខទុក្ខ បង្រៀនព្រះបន្ទូល ដឹកនាំពិធីកាច់នំប៉័ង និងធ្វើពិធីជ្រមុជទឹកជាដើម ។

ត្រូវជ្រើសរើសមនុស្ស ដែលមានគុណសម្បត្តិទាំងឡាយ ដែលមានរៀបរាប់នៅក្នុង ១ ធីម៉ូថេ ជំពូកទី ៣ (គឺ គុណសម្បត្តិល្អឥតខ្ចោះ មានភរិយាតែមួយ មិនស្រវឹងស្រា មានចិត្តធ្ងន់ មានកិរិយាមារយាទល្អ ចេះទទួលភ្ញៀវ ចេះបង្រៀន មិនចំណូលស្រា មិនចេះឈ្លោះប្រកែក មានចិត្តសប្បុរស មិនចេះរករឿង មិនស្រឡាញ់ប្រាក់ ចេះមើលខុសត្រូវលើគ្រួសារខ្លួនផ្ទាល់ និងធ្វើឱ្យកូនចៅចេះស្តាប់បង្គាប់) ។

១៣- ក្រុមជំនុំមួយអាចរីកចំរើនឡើងបាន បើសិនជាពួកអ្នកទទួលខុសត្រូវ :

☐ មកពីខាងក្រៅ ។

☐ រស់នៅក្នុងសហគមន៍របស់ក្រុមជំនុំនោះ ។

១៤- ក្រុមជំនុំទាំងឡាយត្រូវតែងតាំងគ្រូគង្វាល :

☐ ដោយប្រញាប់ប្រញាល់ ។

☐ ដោយប្រុងប្រយ័ត្ន ។

១៥- បើអ្នកចាស់ទុំទៅសួរសុខទុក្ខស្ត្រីណាម្នាក់ គាត់ត្រូវទៅ :

☐ តែឯង ។

☐ ដោយមានគ្នា ។

១៦- នៅក្នុងកម្មវិធីថ្វាយបង្គំពិសេស សំរាប់តែងតាំងអ្នកចាស់ទុំថ្មីណាម្នាក់ គេត្រូវថ្វាយអ្នកចាស់ទុំថ្មីនោះទៅព្រះជាម្ចាស់ និងបង្ហាញអោយក្រុមជំនុំស្គាល់ ដើម្បីអោយគាត់ :

☐ អធិប្បាយ ។

☐ សន្យាថា នឹងបំពេញភារៈកិច្ចរបស់គាត់ ។

© Project WorldReach © SEAN

៩- ការងារផ្សាយដំណឹងល្អ និងការកសាងគ្រីស្តជនអោយរីកចំរើនឡើងអាចស៊ីសង្វាក់គ្នា បើសិនជា :

☐ យើងអប់រំប្រៀនប្រដៅជានិច្ច ។

☐ យើងអធិប្បាយយូរវែង ។

១០- បើសិនជាគ្រីស្តជនណាម្នាក់ធ្វើអំពើបាប ក្រុមជំនុំ :

☐ អោយគាត់បំពេញភារៈកិច្ចកាន់តែច្រើន ។

☐ កែតម្រូវគាត់ ។

១១- តាមធម្មតា ក្រុមជំនុំនិមួយៗរបស់ពួកសាវក ដឹកនាំដោយ :

☐ អ្នកចាស់ទុំច្រើននាក់ ។

☐ អ្នកចាស់ទុំតែម្នាក់ប៉ុណ្ណោះ ។

១២- ជួនកាលក្រុមជំនុំថ្មី គ្មានអ្នកបំរើក្រុមជំនុំដែលបានហាត់រៀនទេ ដូចនេះពួកអ្នកជឿថ្មី ដែលទទួលបន្ទុកកិច្ចការត្រួតពិនិត្យ ត្រូវបង្កើតជា :

☐ គណៈកម្មាធិការបណ្តោះអាសន្ន ។

☐ គណៈកម្មាធិការអចិន្ត្រៃយ៍ ។

ហេតុអ្វីបានជាត្រូវចាត់តាំងអ្នកចាស់ទុំច្រើនគ្នា ?

គំនិតដែលអោយតែគ្រូគង្វាលម្នាក់ ឬអ្នកចាស់ទុំតែម្នាក់ធ្វើកិច្ចការគ្រប់យ៉ាង មិនត្រូវតាមព្រះគម្ពីរទេ ។ គ្រូគង្វាលដែលអោយតំលៃខ្លួនឯងទាប មិនហ៊ានប្រគល់កិច្ចការដល់មនុស្សឯទៀតធ្វើទេ ពីព្រោះគាត់ខ្លាចបាត់បង់អំណាចរបស់ខ្លួន ដូច្នេះ គាត់ត្រួតត្រាច្រើនជាងគ្រប់គ្រងលើសមាជិករបស់ខ្លួន ។ ឯគ្រូគង្វាលដែលវៃឆ្លាត ចេះណែនាំចាស់ទុំទាំងអស់ ឱ្យអាចចូលរួមធ្វើកិច្ចការឃ្វាលដែរ ។

ក្រុមជំនុំថ្មី ដែលនៅតំបន់ឆ្ងាយដាច់ស្រយាល មិនសូវមានគ្រូគង្វាល ដែលបានទទួលការបង្ហាត់បង្រៀនទេ ។ ក្រុមជំនុំទាំងនោះ អាចរៀបចំអោយមាន**គណៈកម្មាធិការបណ្តោះអាសន្នមួយ** ដោយជ្រើសតាំងពួកអ្នកចាស់ទុំថ្មី ។ គណៈកម្មាធិការនេះ នឹងត្រួតពិនិត្យមើលការងារក្នុងក្រុមជំនុំ (កិច្ចការ ១៤:២៣, ២០:១៧-២៨, ទីតុស ១:៥) ។

បើសិនជាពួកអ្នកចាស់ទុំទាំងនោះជាគ្រីស្តជនថ្មី ពួកគេមិនត្រូវខិតខំអធិប្បាយតាមទម្រង់របស់ពួកគ្រូអធិប្បាយ ដែលមានបទ-ពិសោធន៍នោះទេ ។ ពួកគេគ្រាន់តែបង្រៀនព្រះគម្ពីរតាមរបៀបស្រួលៗបានហើយ ។ ពួកអ្នកចាស់ទុំនៅក្នុងក្រុមបណ្តោះអាសន្ន

នេះ ត្រូវធ្វើកិច្ចការឃ្វាល និង កិច្ចការដឹកនាំក្រោមការត្រួតពិនិត្យ ។ ក្រុមជំនុំខ្លះអនុញ្ញាតិអោយពួកគេដឹកនាំពិធីកាច់នំប៉័ង នៅពេលដែលគ្មានគ្រូគង្វាលពេញសិទ្ធិ ។

អ្នកចាស់ទុំដែលមិនទាន់បានហាត់រៀនគ្រាប់គ្រាន់ ត្រូវទទួលខុសត្រូវកាន់តែច្រើនបន្តិចម្តងៗ ស្របទៅតាមបទពិសោធន៍ និង សមត្ថភាពរបស់គាត់ ។ ពេលអ្នកចាស់ទុំនោះបានទទួលការហាត់រៀនហើយ គេអាច «តែងតាំងគាត់ »ដោយអធិស្ឋានដាក់ដៃលើគាត់ ហើយអនុញ្ញាតិអោយគាត់អធិប្បាយ ធ្វើពិធីជ្រមុជទឹក និង កិច្ចការឃ្វាលផ្សេងៗទៀត ជាគ្រូគង្វាល (១ ធីម៉ូថេ ៤:១៤) ។



៥- សមាជិកម្នាក់ អាចក្លាយជាអ្នកដឹកនាំ ដោយសារ :

☐ គាត់តែងតាំងខ្លួនឯង ។

☐ ក្រុមជំនុំតែងតាំងគាត់ ។

៦- ពួកអ្នកជំនួយត្រូវ :

☐ ជួយគ្រូគង្វាល ។

☐ ត្រួតត្រាលើក្រុមជំនុំ ។

៧- ដើម្បីអាចក្លាយជាក្រុមជំនុំ ដែលចេះប្រតិបត្តិតាមព្រះជា-ម្ចាស់ យើងត្រូវប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត ដែលក្នុងនោះមានពិធីជ្រមុជទឹក និង :

☐ ពិធីកាច់នំប៉័ង ។

☐ ក្រិត្យវិន័យអំពីពិធីបុណ្យរបស់សម្ពន្ធមេត្រីចាស់ ។

៨- អ្នកដឹកនាំថ្មីត្រូវ :

☐ ធ្វើការងារទាំងអស់ ដោយខ្លួនឯង ។

☐ បង្រៀនសមាជិកក្រុមជំនុំទាំងអស់ អោយចេះចូលរួមធ្វើការជាមួយគ្នា ។

© Project WorldReach © SEAN

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- ព្រះគ្រីស្តជាម្ចាស់ និងជាមេបញ្ជាការនៃក្រុមជំនុំរបស់ព្រះអង្គ ។ ព្រះអង្គដឹកនាំក្រុមជំនុំដោយ :

- ☐ អាថិកំបាំងរបស់ព្រះអង្គ ។
- ☐ សេចក្តីបង្គាប់របស់ព្រះអង្គ ។

២- យើងត្រូវអំពាវហៅមនុស្សអោយ :

- ☐ ទន្ទេញទំនុកតម្កើងអោយចាំ ។
- ☐ ប្រតិបត្តិតាមព្រះគ្រីស្ត ។

៣- យើងត្រូវប្រតិបត្តិតាម :

- ☐ សេចក្តីបង្គាប់របស់ព្រះគ្រីស្ត ។
- ☐ ទំនៀមទំលាប់របស់មនុស្ស ។

៤- ព្រះជាម្ចាស់ប្រទានអំណោយទានដល់ :

- ☐ អ្នកជឿទាំងអស់ ។
- ☐ តែអ្នកចាស់ទុំខ្លះប៉ុណ្ណោះ ។

ពេលបង្កើតក្រុមជំនុំថ្មីមួយ ត្រូវអោយអ្នកចាស់ទុំថ្មីសិក្សា និងមានការទទួលខុសត្រូវ (ភារៈកិច្ច)កាន់តែច្រើនបន្តិចម្តងៗ ។ ធ្វើដូចនេះ នាំអោយក្រុមជំនុំរបស់គេរឹងមាំ ។ ការដែលក្នុងក្រុមជំនុំមានអ្នកចាស់ទុំដែលបានទទួលការបង្ហាត់បង្រៀន និងដឹកនាំក្រុមជំនុំនោះ ប្រសើរជាងការអញ្ជើញអ្នកក្រៅអោយមកបំពេញកិច្ចការឃ្វាលជំនួសអ្នកចាស់ទុំក្នុងក្រុមជំនុំ ។ ក្រុមថ្មីរបស់អ្នកជឿត្រូវរៀបចំជាក្រុមជំនុំយ៉ាងឆាប់បំផុត តាមដែលអាចធ្វើទៅបាន គឺថារៀបចំជាក្រុមជំនុំដែលមានសាវ័ក ដែលបានទទួលពិធីជ្រមុជទឹករួចហើយ ហើយដែលចេះប្រតិបត្តិតាមព្រះជាម្ចាស់ (ម៉ាថាយ ២៨:១៩-២០) ។

របៀបជ្រើសរើសអ្នកចាស់ទុំថ្មី

ដើម្បីចាត់តាំងអ្នកបំរើកិច្ចការឃ្វាលណាម្នាក់ ជាអ្នកចាស់ទុំ អ្នកដែលចាត់តាំងនោះ ត្រូវសង្កេតមើលជីវិត និងការងារបំរើព្រះ-ជាម្ចាស់របស់អ្នកនោះសិន មុននឹងចាត់តាំង ។

ការដែលឆាប់តែងតាំងគ្រីស្តជនណាម្នាក់ ជាអ្នកចាស់ទុំពេកបណ្តាលអោយមានបញ្ហា ។ មុននឹងមានឱកាសធ្វើជាអ្នកចាស់ទុំ អ្នកនោះត្រូវបង្ហាញអោយឃើញថា គាត់ជាមនុស្សស្មោះត្រង់នឹងភារៈកិច្ច និងចេះបន្ទាបខ្លួនសិន (១ ធីម៉ូថេ ៣:៦) ។



បើសិនជាក្រុមជំនុំពន្យារពេលយូរពេក មិនតែងតាំងអ្នកបំរើដែលបង្ហាញលក្ខណៈល្អតាមតម្រូវការ ហើយដែលព្រះជាម្ចាស់កំពុងប្រើនោះ ក៏នាំអោយមានបញ្ហាដែរ ។ ដើម្បីជ្រើសរើស ឬទទួលស្គាល់ជាអ្នកចាស់ទុំ និងជាអ្នកបំរើកិច្ចការពិសេស ក្រុមជំនុំដំបូងរបស់ពួកសាវ័ក តមអាហារ និងអធិស្ឋាន (កិច្ចការ ១៣:២-៣, ១៤:២៣) ។ មុននឹងជ្រើសរើសសាវ័ក ព្រះយេស៊ូបានយាងឡើងទៅលើភ្នំ ដើម្បីអធិស្ឋានពេញមួយយប់ (លូកា ៦:១២-១៦) ។

យើងតែងតាំងពួកសមាជិក ដែលមានលក្ខណៈសម្បត្តិដូចមានរៀបរាប់នៅក្នុង ១ ធីម៉ូថេ ៣:១-៧ ជាអ្នកចាស់ទុំ :

ឧទាហរណ៍ : សមាជិកមួយចំនួនអាចធ្វើជា «អ្នកជំនួយ» ។ ពួកគេអាចទៅសួរសុខទុក្ខ ជួយអ្នកខ្វះខាត ទៅលេងអ្នកជម្ងឺ ថែរក្សាសម្ភារៈរបស់ក្រុមជំនុំ រៀបចំធ្វើពិធីកាច់នំប៉័ង សំអាតអាគារព្រះវិហារ និង បង្រៀនមនុស្សឯទៀត ។ល។ (កិច្ចការ ៦:១-៧, រ៉ូម ១៦:១-២, ១ ធីម៉ូថេ ៣:៨-១៣) ។



ផ្នែកផ្សេងៗរបស់រូបកាយ មានមុខនាទីផ្សេងៗគ្នា ឯការងាររបស់ព្រះគ្រីស្ត ក៏ត្រូវបំពេញដោយសារអំណោយទានខាងព្រលឹងវិញ្ញាណផ្សេងៗដែរ (១ កូរិនថូស ១២:៤-២៧) ។

សមាជិកម្នាក់ៗរបស់រូបកាយ យ៉ាងតិចក៏មានអំណោយទានមួយដែរ ។ សូមលើកទឹកចិត្ត និងជួយបងប្អូនសមាជិកទាំងអស់អោយដឹងពីអំណោយទានរបស់គេ និងឱ្យបំរើព្រះជាម្ចាស់ និងមនុស្សឯទៀត ដោយអំណោយទានទាំងនោះ (អេភេសូ ៤:១-១៦, ១ ពេត្រុស ៤:១០-១១) ។

លទ្ធផលនៃការដែលបងប្អូនសមាជិកទាំងអស់ ចេះបំរើព្រះជាម្ចាស់ ដោយអំណោយទានរបស់ខ្លួន គឺក្រុមជំនុំនឹងមានកិច្ចការបំរើផ្សេងៗ កម្មវិធីថ្វាយបង្គំដែលកសាងអ្នកជឿ និងការងារគ្រីស្តជនច្រើនយ៉ាង នៅក្នុងរយៈពេលមួយអាទិត្យៗ ។

☐ សូមអាន រ៉ូម ១២:៤-៨ ។

- លក្ខណៈសម្បត្តិទីមួយ គឺមានគុណសម្បត្តិល្អឥតខ្ចោះ ។ គ្មាននរណាអាចចាប់កំហុសអ្នក ដែលមានគុណសម្បត្តិល្អឥតខ្ចោះទេ ពីព្រោះជីវិតគាត់ ទាំងនៅក្នុងក្រុមជំនុំ ទាំងនៅក្នុងសង្គម មានភាពបរិសុទ្ធ ។ ភាពបរិសុទ្ធពិតដូចនេះអាចកើតមាន ដោយសារជីវិតយើងបានពោរពេញ ដោយព្រះ-វិញ្ញាណដ៏វិសុទ្ធ ។
- លក្ខណៈសម្បត្តិទីពីរ គឺត្រូវមានភរិយាតែមួយ ។ សេចក្តីល្បួងខាងផ្លូវកាមគុណអាចបំផ្លាញជីវិត និងកិច្ចការបំរើរបស់អ្នកចាស់ទុំ ។ អ្នកចាស់ទុំម្នាក់ៗត្រូវដឹងអំពីភាពទន់ខ្សោយរបស់ខ្លួន ហើយប្រុងប្រយ័ត្ន ។ ពេលនោះ អារក្សមិនអាចបំផ្លាញគាត់បានឡើយ ដោយសារគាត់ប្រុងស្មារតីជានិច្ច ។

  អ្នកចាស់ទុំឈ្លាសវៃ មិនទៅសួរសុខទុក្ខស្ត្រីតែឯងទេ ហើយទោះជាទៅជាមួយអ្នកឯទៀត ក៏មិនទៅសួរសុខទុក្ខស្ត្រីណាម្នាក់ញឹកញាប់ដែរ ។ គាត់មិនត្រូវអានទស្សនាវដ្តី ឬក៏មើលភាពយន្តរបស់លោកីយ៍ ដែលទាក់ទងនឹងរឿងអាស-អាភាសដែរ ។ ការទាំងនេះ បង្កើតអោយមានបំណងខ្លាំងក្លាចំពោះអ្វីៗ ដែលខុសនឹងព្រះគម្ពីរ ហើយទាស់នឹងព្រះ-ជាម្ចាស់ ។ ព្រះគម្ពីរហៅអំពើអាក្រក់នេះថា «ការត្រេកត្រអាលនឹងកាមគុណថោកទាប» ។

សូមអាន និងសរសេរលក្ខណៈសម្បត្តិផ្សេងៗទៀត សំរាប់តែងតាំងអ្នកចាស់ទុំ ដូចមានរៀបរាប់នៅក្នុង ១ ធីម៉ូថេ ៣:១-៧ និង ទីតុស ១:៥-៩ ។

ក្រុមជំនុំខ្លះជ្រើសរើសអ្នកចាស់ទុំ ឱ្យបំរើការងារសំរាប់រយៈពេលជាក់លាក់ (ឧទាហរណ៍ សំរាប់រយៈពេល ៦ ឆ្នាំ) ។

ជំហានទីប្រាំ

ជំហានទីប្រាំនៃការរៀបចំក្រុមជំនុំថ្មី គឺ : **លើកទឹកចិត្ត និងជួយអោយសមាជិករបស់ខ្លួនទាំងអស់ យកអំណោយទានរបស់ខ្លួនមកអនុវត្ត** ។

របៀបបំពេញកិច្ចការបំរើផ្សេងៗរបស់ក្រុមជំនុំ :



© Project WorldReach © SEAN

- បើសិនជាអ្នកនោះមិនព្រមស្តាប់ពួកអ្នកទាំងនោះទៀត សូមប្រាប់អំពីហេតុការណ៍នេះដល់ក្រុមជំនុំទាំងមូល ក្នុងពេលប្រជុំ ។ បើសិនជាអ្នកនោះនៅតែមិនកែប្រែចិត្តគំនិត ត្រូវលែងអោយគាត់ធ្វើជាសមាជិកក្រុមជំនុំទៀត (ម៉ាថាយ ១៨:១៧-១៨) ។



ការតែងតាំងអ្នកចាស់ទុំថ្មី

សូមអោយអ្នកចាស់ទុំម្នាក់ៗ សន្យានៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ និងក្រុមជំនុំថា នឹងបំពេញភារៈកិច្ចឃ្វាលរបស់ខ្លួន ។ ក្រុមជំនុំក៏ត្រូវសន្យាថា នឹងធ្វើតាមការដឹកនាំរបស់អ្នកចាស់ទុំ និងគាំទ្រកិច្ចការបំរើដែលគាត់ធ្វើដែរ ។ ទូលសុំអោយព្រះជាម្ចាស់បំពេញអ្នកចាស់ទុំថ្មី ដោយព្រះវិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ និងប្រទានអោយពួកគេមានអំណោយទាន ដែលពួកគេត្រូវការសំរាប់បំពេញភារៈកិច្ចរបស់ពួកគេ ។



ភារៈកិច្ចរបស់អ្នកចាស់ទុំម្នាក់ៗ

យើងមិនមែនតែងតាំងអ្នកចាស់ទុំម្នាក់ ដើម្បីអោយគេមានឋានៈខ្ពស់នោះទេ តែគឺដើម្បីឱ្យគេធ្វើកិច្ចការឃ្វាល ។ ការដែលសំខាន់មិនមែនឋានៈគាត់ជាអ្នកណាទេ តែជាការដែលគាត់បំពេញភារៈ-កិច្ចរបស់គាត់ ដូចដែលមានចែងក្នុងព្រះគម្ពីរទៅវិញទេ ។

អ្នកចាស់ទុំខ្លះ មកចូលរួមក្នុងការប្រជុំគណៈកម្មាធិការ តែមិនបានបំពេញកិច្ចការឃ្វាល ដូចដែលព្រះគម្ពីរបង្គាប់នោះទេ ។ ជួនកាលពួកគេមិនទាំងដឹងថា ខ្លួនត្រូវមានភារៈកិច្ចអ្វីខ្លះផង ។ ពួកអ្នកទាំងនោះគ្រាន់តែប្រើឋានៈរបស់ខ្លួន ដើម្បីត្រួតត្រាលើក្រុមជំនុំប៉ុណ្ណោះ ។ នេះមិនមែនជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ (១ ពេត្រុស ៥:៣) ។

ភារៈកិច្ចពិតរបស់អ្នកចាស់ទុំ មាន :

- ភារៈកិច្ចដំបូងបង្អស់ គឺជួយសមាជិកទាំងអស់របស់ក្រុមជំនុំ ឬក្រុមអោយអាចបំពេញភារៈកិច្ចជាគ្រីស្តជនរបស់ពួកគេ ។ (កិច្ចការ ២០:១៧,២៨,៣១ និង ១ ពេត្រុស ៥:១-៤)។

គោលដៅរបស់ការអប់រំដោយកែតម្រូវ មិនមែនជាការបំផ្លាញទេ តែជាការកែប្រែ និងស្តារឡើងវិញ ។ ១ កូរិនថូស ៥:៥ ទូន្មានយើងអោយប្រៀនប្រដៅមនុស្សដែលបានធ្វើបាប ដើម្បីអោយការឈឺចាប់ ដែលបណ្តាលមកពីការប្រៀនប្រដៅនោះ នាំអោយគេកែប្រែចិត្តគំនិត ។

ជំហាននៃការអប់រំប្រៀនប្រដៅគ្រីស្តជនណាម្នាក់ ដែលមានកំហុស គឺ :

- ជំបួង និយាយជាមួយគាត់តែឯងសិន ។ សូមកុំធ្វើអោយមានការរំជើបរំជួល ដោយសារអ្នកដើរទៅនិយាយរឿងនេះប្រាប់មនុស្សឯទៀត គឺកុំទិតៀនអ្នកដែលមានកំហុសនោះនៅចំពោះមុខមនុស្សឯទៀត ។ បើសិនជាអ្នកគ្មានសេចក្តីក្លាហានទៅនិយាយផ្ទាល់ជាមួយអ្នក ដែលមានកំហុសទេ សូមនៅស្ងៀមកុំមាត់ (ម៉ាថាយ ៧:១, ១៨:១៥) ។
- បើសិនជាអ្នកនោះមិនព្រមស្តាប់អ្នកទេ សូមនាំបងប្អូនចាស់ទុំម្នាក់ ឬពីរនាក់ទៅជាមួយ ដើម្បីជួយជាស់តឿន អ្នកដែលមានកំហុសនោះ ។ ត្រូវធ្វើការទាំងអស់នេះ ដោយទឹកចិត្តស្លូតបូត និងដោយសេចក្តីស្រឡាញ់ (ម៉ាថាយ ១៨:១៦, កាឡាទី ៦:១) ។

ទុំអប់រំ ដោយការណែនាំ នោះក្រុមជំនុំមិនសូវត្រូវអប់រំ ដោយការកែតម្រូវទេ ។ ព្រោះអ្វី ?

_____

_____

_____

_____

_____

ទោះជាយ៉ាងនោះក៏ដោយ ក៏នៅតែត្រូវការការអប់រំ ដោយកែតម្រូវជានិច្ច ។ ព្រះអម្ចាស់យេស៊ូមានបន្ទូលថា÷ *«ហេតុផ្សេងៗ ដែលនាំអោយគេប្រព្រឹត្តអំពើបាបនោះ ត្រូវតែមានចៀសមិនផុត ប៉ុន្តែ អ្នកណានាំគេអោយប្រព្រឹត្តអំពើបាប អ្នកនោះត្រូវវេទនាហើយ !»* (ម៉ាថាយ ១៨:៧) ។

អំពើបាបមានឥទ្ធិពលអាក្រក់លើក្រុមជំនុំមែន ប៉ុន្តែ អាចមានលទ្ធផលអាក្រក់ខ្លាំងជាបន្ត បើសិនជាពួកអ្នកចាស់ទុំមិនអប់រំប្រៀនប្រដៅ ។ បើសិនជាពួកអ្នកចាស់ទុំមិនកែតម្រូវមនុស្សដែលប្រព្រឹត្តអំពើបាប នោះសមាជិកទាំងអស់នឹងមានកំហុស ហើយឥទ្ធិពលអាក្រក់នឹងមានរហូត ។

- ចាត់ចែងការងារក្នុងក្រុមជំនុំ ។ អ្នកចាស់ទុំម្នាក់មិនត្រូវធ្វើកិច្ចការទាំងអស់តែឯងទេ គឺគាត់ត្រូវជំរុញទឹកចិត្ត និងធ្វើយ៉ាងណា អោយអ្នកឯទៀតចូលរួមធ្វើកិច្ចការជាមួយដែរ ។ ដើម្បីអាចចាត់ចែងការងារក្រុមជំនុំបាន ពួកអ្នកចាស់ទុំត្រូវជួបប្រជុំជាទៀងទាត់ ។
- បង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ : (ទីតុស ១:៩ និង ១ ពេត្រុស ៥:២) ។
- គ្រប់គ្រងជីកនាំក្រុមជំនុំ (១ ធីម៉ូថេ ៥:១៧) ។
- ទៅសួរសុខទុក្ខអ្នកជម្ងឺ (យ៉ាកុប ៥:១៤-១៥) ។



- ការពារក្រុមអ្នកជឿពីពួក «ឆ្កែចចក» (កិច្ចការ ២០:២៨-៣១) ។
- ប្រៀនប្រដៅបងប្អូនសមាជិក ដែលបានប្រព្រឹត្តខុស ។

ការបណ្តុះបណ្តាលពួកអ្នកចាស់ទុំ

- អ្នកចាស់ទុំត្រូវការហាត់រៀន ។ តើអ្នកបង្ហាត់បង្រៀនអ្នកចាស់ទុំថ្មី ដោយកម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត» ដែរឬទេ ? _____
- ពួកអ្នកចាស់ទុំត្រូវជួបប្រជុំគ្នា ដើម្បីអធិស្ឋាន និងធ្វើសេចក្តីសំរេច ។
- តើពួកអ្នកចាស់ទុំរបស់អ្នក កំណត់ពេលជួបជុំគ្នាដូចម្តេច ? (រាល់អាទិត្យ មួយខែពីរដង រាល់ខែ ។ល។)

_____

- តើពួកគេមកចូលរួមប្រជុំទាំងអស់គ្នា ជាទៀងទាត់ដែរឬទេ ?

_____

យោងទៅតាម ម៉ាថាយ ១៨:១៥-២០ និងកាឡាទី ៦:១ យើង ត្រូវ :

☐ ស្តីបន្ទោសខ្លាំង ។

☐ កែតំរង់ ។

☐ ដាក់ទោស ។

នៅក្នុងក្រុមជំនុំថ្មី សមាជិករបស់គណៈកម្មាធិការបណ្តោះអាសន្ន ត្រូវ :

☐ អប់រំជាប់ជានិច្ច ។

☐ អោយអ្នកចូលរួមធ្វើតាមចិត្ត ។

ក្រុមជំនុំនិមួយៗត្រូវទទួលខុសត្រូវ ក្នុងការអប់រំប្រៀនប្រដៅសមាជិករបស់ខ្លួនផ្ទាល់ (១ កូរិនថូស ៥:១-៥) ។

ការអប់រំប្រៀនប្រដៅមានពីរយ៉ាង គឺ ការណែនាំ និងការកែ-តម្រូវ ។ ការអប់រំដោយការណែនាំមានន័យថា រៀបចំ បង្រៀន និងចាត់ចែងក្រុមជំនុំទាំងមូល ។ ការអប់រំដោយកែតម្រូវ មានន័យថា កែប្រែ និងស្តារឡើងវិញសមាជិក ដែលមិនចេះស្តាប់បង្គាប់ ឬ ដែលបានប្រព្រឹត្តអំពើបាប ។ បើសិនជាអ្នកចាស់

ក្រុមជំនុំដែលមានការអប់រំល្អ ជាក្រុមជំនុំដែលរីកចំរើនទៅមុខ ។ បើគ្មានការអប់រំទេ ក្រុមជំនុំនឹងដើរខុសផ្លូវ ។

រូបកាយទាំងមូលអាចមានដំណើរការជានិច្ច តាមការអប់រំ ដោយសារបាន**រួមជាមួយព្រះគ្រីស្ត** ។

ជើងរបស់មនុស្សស្រីវិង មិនស្តាប់តាមបញ្ជារបស់ខួរក្បាលខ្លួនឯងទេ ។ ដូចគ្នានេះដែរ បើសិនជាសមាជិកណាមួយរបស់ក្រុមជំនុំមិនបំពេញភារៈកិច្ចខ្លួនទេ នោះធ្វើអោយក្រុមជំនុំចុះខ្សោយ ។

សូមឧបមាថា អ្នកជា «ជើង» មួយរបស់ក្រុមជំនុំ ។ បើអ្នកជំពប់ដួល ក្រុមជំនុំនឹងដើរខ្វើចជើង ។ ដូចនេះ រូបកាយទាំងមូល (ក្រុមជំនុំ) ត្រូវតែមានសុខភាពល្អ មានការរៀបចំល្អ និងមានការអប់រំល្អ ។

ក្នុងការអប់រំ យើងត្រូវកែតំរង់កំហុស និងអំពើបាបរបស់ពួកសមាជិកដែរ ។

ក្រុមជំនុំជួយសមាជិករបស់ខ្លួន អោយអាចបំពេញភារៈកិច្ច**ផ្សាយដំណឹងល្អ**ប្រាប់អ្នកដែលមិនទាន់ជឿ និង**កសាង**ពួកអ្នកជឿអោយរីកចំរើនឡើងជាប់ជានិច្ច ដោយ**សារការអប់រំ** ។

- បើសិនជាអ្នកចាស់ទុំណាម្នាក់មិនសិក្សា មិនមកចូលរួមប្រជុំ ឬ មិនបំពេញភារៈកិច្ចរបស់ខ្លួន តើយើងត្រូវធ្វើដូចម្តេច ?

  _____

  _____

- តើអ្នកបានធ្វើកិច្ចការទាំងនេះឬទេ ? _____

ជំហានទីបី

ជំហានទីបីនៃការរៀបចំក្រុមជំនុំថ្មី គឺ : **បញ្ជូល និង ចាត់ចែងមុខងារបំរើខាងផ្សព្វផ្សាយដំណឹងល្អជាមួយនឹងមុខងារបំរើខាងកសាងពួកអ្នកជឿ** ។

តើក្រុមជំនុំត្រូវរីកចំរើនទៅមុខ ដោយរបៀបណា ?

ជើងទាំងពីរខាងក្រោមនេះ ជានិមិត្តរូបអំពីការរីកចំរើនទៅមុខរបស់ក្រុមជំនុំ ។ ការងាររបស់ក្រុមជំនុំមានពីរផ្នែក គឺការផ្សាយដំណឹងល្អប្រាប់ពិភពលោក និងការកសាងអ្នកជឿអោយរីកចំរើនឡើង ។



ជើងទាំងពីរត្រូវដើរទៅជាមួយគ្នា ដោយស៊ីសង្វាក់គ្នា និងស្មើៗគ្នា ។ **ការផ្សាយដំណឹងល្អប្រាប់ពិភពលោក និងការកសាងពួកអ្នកជឿ**អោយរីកចំរើនឡើង ត្រូវធ្វើឡើងព្រមគ្នា ។ បើធ្វើតែការងារមួយ គ្មានធ្វើមួយទៀតជាមួយគ្នា នោះនាំអោយក្រុមជំនុំផ្អៀងម្ខាង(មិនគ្រប់លក្ខណៈ) បានន័យថា អ្នកជឿថ្មីជាច្រើនមិនជំរីកឡើងជាចាស់ទុំខាងព្រលឹងវិញ្ញាណ ឬមួយក្រុមជំនុំនៅជាក្រុមជំនុំដែលមិនផ្សាយដំណឹងល្អដល់មនុស្សឯទៀត ។

ក្រុមជំនុំផ្សាយដំណឹងល្អប្រាប់ពិភពលោក និងកសាងអ្នកជឿឱ្យរីកចំរើនឡើងព្រមជាមួយគ្នា ប្រៀបដូចជាជើងទាំងពីររបស់រូបកាយមួយ ។

ដើម្បីអាចបំពេញគោលដៅទាំងពីរនេះបាន ពួកអ្នកចាស់ទុំត្រូវឱ្យពួកសមាជិកជួយបំពេញភារៈកិច្ចដូចជា ទៅសួរសុខទុក្ខ ផ្សព្វផ្សាយដំណឹងល្អ បង្រៀនពួកអ្នកជឿថ្មីអោយចេះប្រតិបត្តិតាមព្រះជាម្ចាស់ ឧបត្ថម្ភដល់ការងារគ្រីស្តទូត លើកទឹកចិត្តអ្នកដទៃ និងជួយអ្នកខ្វះខាត ។ល។ ។

ជំហានទីបួន

ជំហានទីបួននៃការរៀបចំក្រុមជំនុំថ្មី គឺ : **អប់រំប្រៀនប្រដៅយ៉ាងមុតមាំ** ។

តើយើងត្រូវធ្វើដូចម្តេច ដើម្បីអោយក្រុមជំនុំដើរតាមផ្លូវត្រង់ ?

ស្មាមជើងរបស់យើងបង្ហាញថា យើងដើរត្រង់ និងតាមការអប់រំដែរឬអត់ ។

